ភ្នំពេញ ៦ កុម្ភៈ ២០២០

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងទំនប់លួងប្រាបាង បង្កើនក្តីបារម្ភចំពោះការប្រែប្រួលនៃទន្លេមេគង្គក្រោម

ការបំលាស់ទីរបស់ត្រី លំហូរជលសាស្ត្រ និងកំណកកករ (ដីល្បាប់) គឺជាផលប៉ះពាល់ឆ្លងដែន ដែលនឹងកើតមានពីគម្រោងទំនប់វារីអគ្គីសនីនៅលើតួទន្លេមេ ដែលក្រុមអង្គការសង្គមស៊ីវិលកម្ពុជា មានក្តីព្រួយបារម្ភជាខ្លាំង។ ការព្រួយបារម្ភបានកើនឡើងបន្ទាប់ពីប្រទេសឡាវ បានស្នើឲ្យមានការពិគ្រោះយោបល់ទៅលើគម្រោងទំនប់វារីអគ្គីសនីលួងប្រាបាង ជាគម្រោងទី៥ របស់ខ្លួនដែលគ្រោងសាងសង់នៅលើតួទន្លេមេគង្គនៅចុងឆ្នាំ២០២០។

ក្រុមអង្គការសង្គមស៊ីវិល ដែលធ្វើការលើវិស័យអភិបាលកិច្ចទឹកនៅកម្ពុជា បានពិនិត្យឃើញថា គម្រោងដែលបានដាក់ស្នើនេះ រួមជាមួយគម្រោងផ្នែកខាងលើដែលមានស្រាប់ នឹងបង្កផលប៉ះពាល់បន្ថែមទៀតដល់លំហូរជលសាស្ត្រ ដែលធ្វើឲ្យផ្នែកខាងក្រោម នៃទន្លេមេគង្គក្រោមនឹងជួបប្រទះញឹកញាប់នូវកម្រិតលំហូរទឹកទាប ពោលគឺការប្រែប្រួលរបបទឹកហូរមានកម្រិតកាន់តែខ្ពស់។ កង្វះព័ត៌មានពីលំហូរទឹក និងការគ្រប់គ្រងការប្រើប្រាស់ទឹកទន្លេពីសំណាក់ទំនប់ផ្នែកខាងលើរហូតដល់ផ្នែកខាងក្រោម គឺជាមូលហេតុចម្បងដែលនឹងធ្វើឲ្យការប្រែប្រួលរបបទឹកហូរមានកម្រិតកាន់តែខ្ពស់។ ការព្យាករណ៍ភាពប្រែប្រួលនេះនៅមិនទាន់រាប់បញ្ចូលនូវបាតុភូតធម្មជាតិដែលអាចនឹងកើតឡើងនោះទេ។ ក្នុងករណីដែលមានបាតុភូតធម្មជាតិកើតឡើង ដូចជា ទឹកជំនន់ ឬភាពរាំងស្ងួត វានឹងបង្កឲ្យមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ ដែលគម្រោងនេះហាក់មិនទាន់មានវិធានការច្បាស់លាស់ដើម្បីកាត់បន្ថយផលប៉ះពាល់នេះនៅឡើយ។

ទន្ទឹមជាមួយគ្នាផងដែរ ក្រុមអង្គការសង្គមស៊ីវិល ក៏បានពិនិត្យឃើញថា គម្រោងដែលបានស្នើនេះ នឹងរួមចំណែកកាត់បន្ថយជាអតិបរមានូវបរិមាណកំណកកករ ឬដីល្បាប់ ដែលចាក់បំពេញផ្នែកខាងក្រោមនៃទន្លេមេគង្គក្រោម ដែលអាចនឹងបង្កឲ្យមានការបាក់ច្រាំងទន្លេ និងប៉ះពាល់ដល់ការប្រកបរបរកសិកម្មរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមដងទន្លេផ្នែកខាងក្រោម។ ថ្វីបើរបាយការណ៍គម្រោង បានទទួលស្គាល់ពីផលប៉ះពាល់ទៅលើលំហូរកំណកកករ ឬដីល្បាប់ ក៏ប៉ុន្តែរបាយការណ៍មិនបានបង្ហាញពីវិធានការ ឬវិធីសាស្ត្រជាក់លាក់ដែលអាចធ្វើបាន ដើម្បីដោះស្រាយបញ្ហានេះទេ។

ក្រុមអង្គការសង្គមស៊ីវិលកម្ពុជា សំដែងការព្រួយបារម្ភ ចំពោះប្រភេទត្រីបំលាស់ទីដែលអាចនឹងមានផលប៉ះពាល់ដល់ការបំលាស់ទីទៅពងកូននៅទន្លេមេគង្គលើ និងការបំលាស់ទីចុះមកទន្លេមេគង្គក្រោមដើម្បីស្វែងរកចំណី ដោយសារទំនប់វារីអគ្គីសនី។ ថ្វីបើគម្រោងបានបង្ហាញពីការរចនាជណ្តើរត្រីដ៏គួរឲ្យចាប់អារម្មណ៍ ក៏ប៉ុន្តែយើងមិនទាន់ដឹងថា ជណ្តើរត្រីនេះ វានឹងដំណើរការឬអត់។ ការប្រែប្រួលរបបជលសាស្ត្រ វាពិតជាមានទំនាក់ទំនង ជាមួយការបង្កកំណើតរបស់ត្រីដោយសាររបបជលសាស្ត្រទៀងទាត់សម្រួលដល់ការបំលាស់ទីរបស់ត្រី ទៅពងកូន ស្វែងរកចំណី និងរីកធំធាត់នៅតាមដៃទន្លេបឹងបួ ទន្លេមេគង្គក្រោម និងជាពិសេសបឹងទន្លេសាប ដែលជាបេះដូងរបស់កម្ពុជា។

ក្រុមអង្គការសង្គមស៊ីវិលសម្តែងការព្រួយបារម្ភផងដែរ ចំពោះផែនការសាងសង់នៅចុងឆ្នាំ ២០២០ នឹងមិនផ្តល់ពេលគ្រប់គ្រាន់ដើម្បីសិក្សាបន្ថែមទៅលើសំណើរបស់អ្នកពាក់ព័ន្ធឲ្យបានរួចរាល់មុនចាប់ផ្តើមសាងសង់ទំនប់។ ក្រុមអង្គការសង្គមស៊ីវិលកម្ពុជា ទទូចស្នើសុំរដ្ឋាភិបាលឡាវ ម្ចាស់គម្រោង និងគណៈកម្មការទន្លេមេគង្គ ត្រូវផ្តល់នូវដំណោះស្រាយសមស្របចំពោះបញ្ហាឆ្លងដែនដែលបាន លើកឡើងខាងលើ ដើម្បីធានាបាននូវការប្រើប្រាស់ទន្លេមេគង្គឲ្យមានសមភាព និងភាពសមហេតុផល ដែលជាគោលការណ៍គ្រឹះនៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង**

លោក ម៉ក់ ប៊ុនធឿន អ្នកសម្របសម្រួលបណ្តាញសម្ព័ន្ធទន្លេកម្ពុជា
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
ទូរស័ព្ទ (៨៥៥ )១២ ៣៩៦ ០៥០
អ៊ីម៉ែល bunthoeurn@ngoforum.org.kh